**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ០៤៩ សហក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ស្ថានភាពពលរដ្ឋភៀសសឹក ផលប៉ះពាល់លើតំបន់ស៊ីវិលកម្ពុជា
## គិតពីម៉ោង៦ព្រឹក ថ្ងៃទី២២ ដល់ម៉ោង៦ព្រឹក ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមជម្រាបជូនថា ចាប់តាំងពីបទឈប់បាញ់រវាងកម្ពុជា និងថៃ ចូលជាធរមាន កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥មក ភាគីថៃពុំទាន់អនុវត្តពេញលេញតាមសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ នៃគណៈកម្មាធិការព្រំដែនទូទៅ (GBC) នៅឡើយទេ។ **ក្រសួងមហាផ្ទៃ** បានបន្តកត់ត្រាទុក រាល់សកម្មភាពមិនស្មោះត្រង់របស់ភាគីថៃ ទន្ទឹមគ្នានឹងការបន្តយកចិត្តទុកដាក់ដោះស្រាយផលប៉ះពាល់លើប្រជាពលរដ្ឋ និងតំបន់ស៊ីវិល ដោយសារអំពើឈ្លានពាន ជាពិសេសពលរដ្ឋដែលនៅពុំទាន់អាចវិលត្រឡប់ទៅលំនៅឋានវិញបាន។

ក្នុងស្ថានភាពនេះ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមជូនបច្ចុប្បន្នភាពសភាពការណ៍ គិតពីម៉ោង៦ព្រឹក ថ្ងៃទី២២ ដល់ម៉ោង៦ព្រឹក ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦ ដូចខាងក្រោម៖

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** មានពលរដ្ឋភៀសសឹក៣៨នាក់បន្ថែមទៀត បានបន្តវិលត្រឡប់ទៅលំនៅឋានវិញ។ ដូច្នេះ ក្នុងចំណោមពលរដ្ឋភៀសសឹកសរុបជាង៦សែន៤ម៉ឺននាក់ មានជាង៦សែន១ម៉ឺននាក់ ឬ ជាង៩៤% បានវិលត្រឡប់ទៅលំនៅឋានវិញ។ នៅមានពលរដ្ឋចំនួន៣៦.២៨២នាក់ទៀត (ស្ត្រី១៨.៧៨៦នាក់ និងកុមារ ១២.២៧៩នាក់) ពុំទាន់អាចវិលទៅលំនៅឋានវិញ។

**២-ការបន្តផ្អាកសេវាសាធារណៈជាមូលដ្ឋាន៖ ខេត្តឧត្តរមានជ័យ** មានសាលារៀន៨ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព៥ នៅបន្តផ្អាក។ **ខេត្តបន្ទាយមានជ័យ** មានសាលារៀន៥ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១ បន្តផ្អាក។ **ខេត្តព្រះវិហារ** មានសាលារៀន៧ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព២ នៅបន្តផ្អាក។

**៣-ការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** គិតចាប់ពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥មក ការខូចខាតទ្រព្យសម្បត្តិសាធារណៈ និងឯកជន ពុំទាន់មានរបាយការណ៍ថ្មីបន្ថែមលើករណីដែលក្រសួងបានកត់ត្រាទុកនៅឡើយទេ។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** គាំទ្រពេញទំហឹងចំពោះរាជរដ្ឋាភិបាល ដែលបានតវ៉ាជំទាស់ជាថ្មី ប្រឆាំងការឈ្លានពានកាន់កាប់ទឹកដីខុសច្បាប់ជាបន្តបន្ទាប់របស់កងកម្លាំងប្រដាប់អាវុធថៃ ក្រោយបទឈប់បាញ់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ដោយចុងក្រោយនេះទៀត បានធ្វើសកម្មភាពដុតបំផ្លាញលំនៅដ្ឋានពលរដ្ឋខ្មែរនៅតំបន់បឹងត្រកួន ឈូសឆាយដីធ្លី សាងសង់ផ្លូវ និងសំណង់បេតុង លាតសន្ធឹងពីតំបន់ប្រាសាទខ្នារ ឆ្ពោះទៅប្រាសាទតាក្របី និង ចុះវាស់វែង បែងចែកដីធ្លីចំនួន៣កន្លែងដល់ប្រជាពលរដ្ឋខ្លួន នៅចន្លោះបង្គោលព្រំដែនលេខ៤៦ និង៤៧ ក្នុងភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ជាដែនអធិបតេយ្យស្របច្បាប់របស់កម្ពុជា ដូចមានក្នុងផែនទីអនុសញ្ញាបារាំង-សៀម ឆ្នាំ១៩០៤ និងឆ្នាំ១៩០៧។ សកម្មភាពនេះ បានបំពានបន្ថែមទៀតលើអនុស្សរណៈស្តីពីការវាស់វែង និងបោះបង្គោលព្រំដែន ឆ្នាំ២០០០ និងសេចក្តីប្រកាសរួម នៃកិច្ចប្រជុំពិសេសលើកទី៣ របស់គណៈកម្មាធិការព្រំដែនទូទៅ(GBC) កាលពីខែធ្នូ ឆ្នាំ២០២៥។ ភាគីថៃ ត្រូវតែបញ្ឈប់សកម្មភាពខាងលើ ឬនៅតំបន់ផ្សេង និងត្រូវចៀសវាងសកម្មភាពជាឯកតោភាគីបៀបនេះបន្ថែមទៀត។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមអំពាវនាវសាធារណជនជាតិ និងមជ្ឈដ្ឋានអន្តរជាតិ បន្តផ្តល់ការគាំទ្រ និងជឿជាក់លើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី ដើម្បីរកដំណោះស្រាយចំពោះជម្លោះព្រំដែនជាមួយប្រទេសថៃដោយសន្តិវិធី តាមមធ្យោបាយសន្តិភាព ស្របតាមច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងទ្វេភាគី ដោយប្រកាន់គោលការណ៍ **ព្រំដែនមិនត្រូវបានផ្លាស់ប្តូរដោយកម្លាំង** ដូចដែលកម្ពុជាបានអនុវត្តយ៉ាងស្មោះត្រង់ និងក្នុងស្មារតីសហប្រតិបត្តិការយ៉ាងល្អជាមួយប្រទេសជិតខាងផ្សេងទៀត។

ថ្ងៃចន្ទ ៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦